ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ពណ........................ ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០...............

# សេចក្តីជូនដំណឹង

យោងប្រកាសលេខ ២៩៨ ពណ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" តាមប្រព័ន្ធស្វ័យប្រវត្តកម្ម បានអនុញ្ញាតឲ្យផលិតករ ឬអ្នកនាំចេញ បោះពុម្ព(Print)វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់"អេ" ដោយខ្លួនឯង ដើម្បីពង្រឹងដល់ការងារផ្តល់សេវាសាធារណៈឲ្យកាន់តែរហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ហេតុនេះ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជូនដំណឹងដល់ផលិតករ ឬអ្នកនាំចេញ សភាពាណិជ្ជកម្មកម្ពុជា សហព័ន្ធស្រូវអង្ករកម្ពុជា និង សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" ទៅបរទេស ក្រោមប្រព័ន្ធស្វ័យប្រវត្តកម្ម មកចុះកិច្ចសន្យាទទួលយកទម្រង់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ "អេ" ពីក្រសួងពាណិជ្ជកម្ម (នាយកដ្ឋាននាំចេញនាំចូល) តាមតម្រូវការនាំចេញប្រចាំឆមាស។

ជាមួយនេះដែរ ក្រសួងពាណិជ្ជកម្មនឹងរៀបចំកម្មវិធីបណ្តុះបណ្តាលជូនផលិតករ ឬអ្នកនាំចេញ អំពីការស្នើសុំចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម និងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ "អេ" តាមប្រព័ន្ធស្វ័យប្រវត្តកម្ម នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ម៉ោ០០នាទីព្រឹក នៅបន្ទប់បាយ័ន (ជាន់ទី ១) នៃទីស្តីការក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពឯកឧត្តម សុខ សុភ័ក្រ្ត អគ្គនាយកសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ស្នើផលិតករ ឬអ្នកនាំចេញ សភាពាណិជ្ជកម្មកម្ពុជា សហព័ន្ធស្រូវអង្ករកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មេត្តាជ្រាប និងជួយធ្វើការផ្សព្វផ្សាយជូនសមាជិកឲ្យបានជ្រាបជាព័ត៌មាន និងចូលរួម តាមការគួរ។

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*